# ការរៀនស្វែងយល់គោលលទ្ធិ និងគោលការណ៍ទាំងឡាយ

គោលលទ្ធិ និងគោលការណ៍នៃដំណឹងល្អមួយចំនួន គឺត្រូវបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងបទគម្ពីរនេះ ។ គោលលទ្ធិ និងគោលការណ៍ផ្សេងទៀតអាចនឹងមានបង្កប់ន័យនៅក្នុងដំណើររឿងនេះ ហើយរកឃើញតែតាមរយៈការសិក្សាព្រះគម្ពីរទាំងមូល ជំពូកមួយ ឬខគម្ពីរតែមួយគត់ប៉ុណ្ណោះ ។ អ្នកអាចអនុវត្តតាមជំហានសំខាន់ៗខាងក្រោមនៅគ្រប់ពេលដែលអ្នកសិក្សាព្រះគម្ពីរ ដើម្បីជួយឲ្យអ្នកស្វែងរកសេចក្ដីពិតនៃដំណឹងល្អឃើញ ៖

១. អានយឺតៗ និងដោយប្រុងប្រយ័ត្ន ។

២. ស្វែងរកសេចក្ដីពិតដែលបានលើកឡើងយ៉ាងច្បាស់ៗ ។ ជួនកាល ទាំងនេះមានការចង្អុលប្រាប់នៅពេលដែលអ្នកនិពន្ធប្រើពាក្យពេចន៍ដូចជា « ដូច្នេះហើយយើងឃើញថា » « ដូច្នេះ » « ហេតុដូច្នេះហើយ » ឬ « មើលចុះ » ។

៣. រកមើលសេចក្ដីពិតដែលទាក់ទង ។ អ្នកអាចស្វែងរកសេចក្ដីពិតទាំងនេះតាមរយៈការសួរខ្លួនឯងនូវសំណួរនានាដូចខាងក្រោមនេះ ៖

    a. តើមានគំនិត ពាក្យពេចន៍ ឃ្លាដ៏សំខាន់ណាមួយ—ជាពិសេសចំណុចណាមួយដែលជួយអ្នកឲ្យស្គាល់ព្រះវរបិតាសួគ៌ និងផែនការរបស់ទ្រង់ ឬព្រះយេស៊ូវគ្រីស្ទ និងដំណឹងល្អរបស់ទ្រង់បានកាន់តែច្បាស់ ?

    b. តើមានទំនាក់ទំនងអ្វីខ្លះរវាងមូលហេតុ និងលទ្ធផលក្នុងដំណើររឿងនេះ ?

    c. តើអ្វីទៅជាសីលធម៌ ឬគំនិតអប់រំនៃដំណើររឿងនេះ ?

    d. ហេតុអ្វីបានជាអ្នកគិតថា អ្នកនិពន្ធបញ្ចូលព្រឹត្តិការណ៍ ឬវគ្គបទគម្ពីរទាំងនេះ ?

៤. សរសេរនូវពាក្យពេចន៍ផ្ទាល់ខ្លួនអ្នកអំពីអ្វីដែលអ្នកបានរកឃើញ ហើយគូសចំណាំពាក្យទាំងនេះនៅក្នុងបទគម្ពីរដែលបង្រៀនអំពីវា ។

៥. ជញ្ជឹងគិតពីមូលហេតុដែលសេចក្ដីពិតនេះមានសារៈសំខាន់ចំពោះអ្នក ។ អែលឌើរ ជែហ្វ្រី អ័រ ហូឡិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានបង្រៀន ៖



សូមជញ្ជឹងគិត [ និង ] ពិសោធន៍រាល់ពាក្យពេចន៍នីមួយៗ រាល់គ្រាប់ត្បូងខាងព្រះគម្ពីរនីមួយៗ ។ . . . កាន់វាឲ្យចំពន្លឺ និងបើកវា មើល និងស្វែងយល់អ្វីទៅជាចំណាំងផ្លាត និងអ្វីទៅជាចំណាំងបែរ ។ . . . ការពិសោធន៍បែបនេះអាចនឹងរកឃើញកំណប់ទ្រព្យដែលលាក់ទុកក្នុងវាលមួយ គុជដែលមានតម្លៃមហាសាល ។ ( « Students Need Teachers to Guide Them » [ សុន្ទរកថាទៅកាន់អ្នកអប់រំខាងសាសនាក្នុងប្រព័ន្ធអប់រំសាសនាចក្រ ថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ១៩៩២ ] ទំព័រ ៤ )

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© 2024 by Intellectual Reserve, Inc. All rights reserved. PD80007812_258_532-1